# សម្រង់កំណាព្យសរសើរហោមន្តមាស

## (ព្រះស្រីធម្មរាជា ព្រះរាជសម្ភារ)

មើលព្រៃនាដផងស្ទឹង ម្ងប់ត្រឈឹងលូតលាស់ឯង
ខ្យល់បក់ទន់ទន្ទេង លំទោនទងលតាដោយ។
ស្រណោះបុប្ផាករ រៀបកេសរីករុះរោយ
គន្ធាត្រលប់ដោយ វាតាផ្សព្វផ្សាយគន្ធារ។
កន្ទង់ត្រង់ត្រឹបផ្កា ត្រេចវេហាស៍ទ្រហឹងខ្ទរ
ហិចហើរលើព្វង់ អម្ពរដូចតន្ត្រីសម។
ស្រណោះអធ្វាស្វាត់ សឹងសព្វសត្វទីទូរគម
ស្រៀវស្រែកត្រសាក់សម ដូចតន្ត្រីសុខស្ងួត៌នាយ។
គន់គួរស្រណោះណា យើងយាត្រាតំបន់ឆ្ងាយ
ស្រីបស្រួលសាន្តសប្បាយ ដោយតំបន់អនាថា។
ស្រណោះនាដំណើរ តែងវែងដើរដោយព្រឹក្សា
ដើរគោកដើរគង្គា សព្វអន្ទើសឹងសប្បាយ។
ស្រណោះល្បែងព្រឹក្សព្រៃ ព្រឹកវិស័យលេងលោះលាយ
រំហើយក្រសាលសាយ សោមនស្សាសុខសាន្តសល់។
ស្រណោះនាយើងនៅ បងនិងចៅវែងតែងយល់
ស្រណោះដើរដោយកល យើងទាំងពីរសាន្តសាទរ។
ស្រណោះនៅនៃបនិត្យ ត្រេកត្រូវចិត្តស្មើស្មោះស
បិតឋានពនេចរ កបហឫទ័យសោតស្នេហា។៚

